**រាជបណ្ឌិត្យសភាកម្ពុជា**

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## ភាគទី៧ - វគ្គទី២

អត្ថបទចងក្រងដោយៈ លោកស្រី ស៊ិន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



ពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១[1]

---

[1] https://sopheak.wordpress.com/2015/11/30

### ៧-២-សុន្ទរកថារបស់លោករេស៊ីដង់ជាន់ខ្ពស់ (១)

ដោយផ្អែកតាមបណ្ណសារស្ដីពី«បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្ដី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨)»[2]នេះ នៅក្នុងពិធីសម្ពោធមាន សុន្ទរកថាចំនួន៤របស់ចាងហ្វាងរាជការក្រុមមឿង (សាលាក្រុងភ្នំពេញ), រេស៊ីដង់ជាន់ខ្ពស់, ព្រះបាទ សម្ដេចព្រះស៊ីសុវត្ថិ និងចាងហ្វាងក្រុមសមាគមពួកពិជ័យសង្គ្រាមចាស់។ សុន្ទរកថារបស់ចាងហ្វាងរាជ ការក្រុមមឿងបានបង្ហាញនៅក្នុងភាគទី៧ វគ្គទី១រួចហើយ។ សម្រាប់ភាគទី៧ វគ្គទី២នេះ សូមបង្ហាញ សុន្ទរកថារបស់លោករេស៊ីដង់ជាន់ខ្ពស់បារាំង បានចាប់ផ្ដើមដោយការអធិប្បាយរបស់គាត់មុននឹងថ្លែង សុន្ទរកថា ដែលមានខ្លឹមសារដើម ដោយមានការកែសម្រួលមួយចំនួន ដូចខាងក្រោម៖

### ក-សេចក្ដីអធិប្បាយរបស់លោករេស៊ីដង់ជាន់ខ្ពស់[3]

សេចក្ដីអធិប្បាយរបស់លោករេស៊ីដង់ជាន់ខ្ពស់ មានខ្លឹមសារដូចតទៅ៖

ដល់ធ្វើពិធីបុណ្យរួចស្រេចហើយ លោក បូដូវាំង ដែលនៅលើខឿនវិមាន ហើយដែលមានព្រះ ករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ, លោក សាសសាំង, ប៉ាទ្រី, សម្ដេចក្រុមព្រះៗកែវហ្វាមុនីវង្ស, លោក ឌុក្វាំង, អ្នកឧកញ៉ាវាំងវរៈវៀងជ័យជួន, លោកសង្ឃរាជបារាំង ប៊ូស៊ុយ និងគ្រូពេទ្យ វ៉ាល់ឡេត៍ នៅអមជុំវិញ ផង នោះលោក បូឌូវាំង ក្រោកឈរឡើងដើម្បីសូត្រសេចក្ដីអធិប្បាយរបស់លោក។

គេមើលទៅឃើញ លោករេស៊ីដង់ជាន់ខ្ពស់ រំជួលក្នុងចិត្តជាខ្លាំង។ ឯសេចក្ដីរំជួលយ៉ាងនេះក៏ងាយ នឹងយល់ ត្បិតលោកបានស្គាល់ជាច្រើនក្នុងពួកជំទង់ ដែលលោករៀបនឹងអធិប្បាយអំពីសេចក្ដីដែលជំទង់ នោះរងទុក្ខវេទនាជាយូរហើយមរណៈទៅ និងអំពីផលបុណ្យប្រសើររបស់ជំទង់ទាំងនោះ។ ប៉ុន្តែដល់ចេញ អធិប្បាយទៅ លោកក៏បានអធិប្បាយសំឡេងឮច្បាស់ជាប្រាកដ។

---

[2] បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្ដី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៨២-៨៨។

[3] គួររំលឹកថា មុននឹងមានអត្ថាធិប្បាយរបស់លោករេស៊ីដង់ជាន់ខ្ពស់ គេបានបើកក្រណាត់គ្របវិមានចេញ ហើយ គេបានចែកទង់ជ័យឱ្យពួកទាហានពិជ័យសង្គ្រាមដែលមាននៅក្នុងទឹកដីក្រោមការគ្រប់គ្រងរបស់បារាំងទាំងប៉ុន្មា ន។ នៅវេលាដែលលោករេស៊ីដង់ជាន់ខ្ពស់ កំពុងតែចែកទង់ជ័យនោះ លោកសក្កិ៥(បូវ៉ែល) ជាអ្នកនាយកស្ដីទីទ័ព ចំណែកខាងស្រុកកូសាំងស៊ីននិងស្រុកខ្មែរ ចាត់ចែងបង្គាប់ឱ្យពួកទាហានគំនាប់។

ដល់បានអធិប្បាយស្តាយ២ម៉ាត់៣ម៉ាត់ អំពីលោកគូវែរណឺរ យេណេរ៉ាល់[4] ដែលពុំបានអញ្ជើញមកដោយមានរវល់នៅក្រុងតុងកឹងនោះ លោករេស៊ីដង់ជាន់ខ្ពស់ បាននិយាយរៀបរាប់ពីការដែលជាងរចនាឈ្មោះ ឌូក្វាំង( Ducoing )បានធ្វើ ហើយលោកមានសេចក្តីសរសើរជាច្រើន។ ស្រេចហើយលោកចាប់អធិប្បាយអំពីគំនិតជាងរចនាដ៏ប្រសើរនេះ គឺគំនិតដែលបណ្តាលនាំឱ្យធ្វើវិមាននេះឡើង ដែលជាការនាំឱ្យសាសន៍ទាំង២ ចូលរួបរួមគ្នាពុំគប្បីញែកចេញបានឡើយ ព្រមទាំងសេចក្តីកតញ្ញូដឹងគុណដល់បុគ្គលដែលស៊ូដល់នៅសេចក្តីស្លាប់ ដើម្បីស្រោចស្រង់សេចក្តីចេះដឹងក្នុងជំពូទ្វីបមនុស្សយើង ហើយនឹងសេចក្តីដែលសាសន៍ទាំងអស់គ្នាត្រូវរួចខ្លួនធ្វើអ្វីបានតាមចិត្ត។

ស្រេចហើយទើបមានសេចក្តីសរសើរជាច្រើនដល់នគរបារាំងសែស។ ឯនគរបារាំងសែសមានគំនិតឈ្វេងយល់ឃើញថាសេចក្តីដែលបញ្ចុះបញ្ចូលដោយសង្កត់សង្កិនបង្ខំនេះ ជាការពុំគួរមានឡើយ។ ប៉ុន្តែគប្បីមានការបញ្ចុះបញ្ចូលចិត្តឱ្យបានយល់ ទើបប្រសើរជាង។ នៅនគរខ្មែរក្តី នគរឆ្លងសមុទ្រ[5]ឯទៀតដែលនៅក្នុងអាណាព្យាបាលបារាំងក្តី នគរបារាំងសែសបានធ្វើយ៉ាងដូច្នេះឯងទាំងអស់ លើបណ្តារាស្ត្រទាំងអម្បាលម៉ាន នគរបារាំងសែសនាំសេចក្តីសុខដល់ពពួកក្រុមក្នុងរបៀបរៀបរយ និងសុខក្សេមក្សាន្តឥតមានបង្ខំអ្វីឡើយ ព្រោះបានកាន់នៅសេចក្តីមេត្តាករុណា សេចក្តីឱ្យរួចខ្លួនទីទៃៗ ហើយនឹងសេចក្តីសប្បុរសដែលបានប្រព្រឹត្តលើនគរទាំងអស់។ នៅស្រុកខ្មែរអំពីដើមមានទ័ពពីប្រទេសក្រៅចូលមកលុកក្នុងនគរ ហើយនិងមានច្បាំងគ្នាក្នុងស្រុកជាច្រើនរយឆ្នាំ ឥឡូវនគរបារាំងសែស បានធ្វើឱ្យបានសេចក្តីសុខនិងបានស្តារប្រទេសឡើងវិញបន្ទាប់ពីទទួលរងការខូចខាតពីសម័យមុន។ រាល់ថ្ងៃនគរបារាំងសែសធ្វើឱ្យចម្រើនពីការដែលរកឃើញក្នុងវិស័យវេជ្ជសាស្ត្រ ដើម្បីបំបាត់រោគឆ្លង ដែលបណ្តាលឱ្យមរណភាពជាច្រើនក្នុងស្រុកពីដើម។ ក្រៅអំពីការទាំងនេះ នគរអាណាព្យាបាលបានចាត់ចែងថែរក្សាប្រាសាទក្បាច់រចនា ជាកេរដំណែលសេចក្តីចេះដឹងនៃជាតិខេមរៈពីដើម ហើយបានរក្សាសេចក្តីជឿរបស់រាស្ត្រក្នុងទំនុកបម្រុងឱ្យនៅដូចដើម។ សេចក្តីអធិប្បាយរបស់លោករេស៊ីដង់ជាន់ខ្ពស់ ចប់ត្រឹមនេះ។

គួររំលឹកថា លុះបានអធិប្បាយទូន្មានពន្យល់ដល់បណ្តាពួកជំទង់ដែលត្រូវតែធ្វើការជាតំណពីរបស់បុគ្គលដែលស្លាប់នោះតទៅទៀតនោះ លោករេស៊ីដង់ជាន់ខ្ពស់ បានសម្តែងបញ្ចប់សេចក្តីអធិប្បាយរបស់លោក ហើយលោកបាននិយាយនឹកគុណដល់អ្នកដែលស្លាប់ក្នុងនគរទាំង២ នេះម្តងទៀត ដោយសេចក្តី

---

[4] លោកគូវែរណឺរយេណេរ៉ាល់(Gouverneur Général) គឺលោកអគ្គទេសាភិបាលឥណ្ឌូចិនដែលគ្រប់គ្រងលើរដ្ឋ៥: កូសាំងស៊ីន, កម្ពុជា, អណ្ណាម, តុងកឹង និងឡាវ។

[5] នគរឆ្លងសមុទ្រគឺ«ទឹកដីឯនាយសមុទ្រ»(Territoire d’Outre-Mer/Overseas Territory) នៅក្រោមការគ្រប់គ្រងរបស់បារាំង។

នឹកគុណពីកិរិយាដ៏ប្រសើរ និងសេចក្តីដែលបុគ្គលទាំងនេះបានស៊ូយ៉ាងដូច្នេះ បណ្តាជននៅឯក្រោយគង់មានចិត្តចាំពុំភ្លេចតាំងពីនេះតទៅ។ បុគ្គលទាំងនេះជាអ្នកនាំផ្លូវ ដែលបណ្តាជននៅឯក្រោយគង់មានចិត្តចាំពុំភ្លេចតាំងពីនេះតទៅ។ បុគ្គលទាំងនេះជាអ្នកនាំផ្លូវ ដែលបណ្តាជននៅឯក្រោយជាតំណ និងយកតម្រាប់តាមក្នុងគ្រាក្រីក្រ។

សេចក្តីបរិយាយខ្លីនេះមិនពេញបរិបូរណ៍ទេ។ លុះបានអធិប្បាយហើយ លោកវេស៊ីដង់ជាន់ខ្ពស់បាននិយាយអំពីនយោបាយបារាំង ដែលនាំឱ្យនគរបារាំងសែសហ៊ាននិយាយអួតថា បានធ្វើឱ្យបណ្តាជនស្រុកខ្មែរចូលចិត្តគ្រប់គ្នាទាំងអស់។

(សូមរង់ចាំអានភាគបន្ត!)